**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

លេខ ...២៥១...............ក.ប/ប្រក

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែ កញ្ញា ឆ្នាំ២០១៣

# ប្រកាស

## ស្តីពី

## សេវារបស់ទីភ្នាក់ងារជ្រើសរើសឯកជននៅកន្លែងធ្វើការ និងការធ្វើមាតុភូមិនិវត្តន៍

## រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

-បានឃើញអនុក្រឹត្យលេខ៥២ អនក្រ.បក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

-បានឃើញអនុក្រឹត្យលេខ១៩០ អនក្រ.បក ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១១ ស្តីពីការគ្រប់គ្រងលើការបញ្ជូនពលករខ្មែរទៅធ្វើការនៅបរទេសតាមរយៈទីភ្នាក់ងារជ្រើសរើសឯកជន

-តាមការចាំបាច់របស់ក្រសួង

## សម្រេច

**ប្រការ១.-**

ប្រកាសនេះកំណត់ពីកាតព្វកិច្ចក្នុងការផ្តល់សេវារបស់ទីភ្នាក់ងារជ្រើសរើសឯកជននៅកន្លែងធ្វើការ និងការធ្វើមាតុភូមិនិវត្តន៍ដើម្បីពង្រឹងប្រសិទ្ធភាពក្នុងការតាមឃ្លាំមើលការសម្របសម្រួល ការដោះស្រាយបញ្ហានានាទាក់ទងនឹងលក្ខខណ្ឌការងារ និង លក្ខខណ្ឌរស់នៅ លក្ខខណ្ឌសុខភាពការរំលោភបំពានផ្សេងៗ ការស្វែងរកនិងជូនដំណឹង អំពីករណីបាត់ខ្លួនរបស់ពលករ ដែលត្រូវបានដាក់ឲ្យធ្វើការនៅបរទេស និងការរៀបចំធ្វើមាតុភូមិនិវត្តន៍របស់ពលករ។

**ប្រការ២.-**

ក្នុងការផ្តល់សេវានៅកន្លែងធ្វើការ ទីភ្នាក់ងារជ្រើសរើសឯកជននីមួយៗត្រូវចាត់ឲ្យមានអ្នកតំណាងអចិន្ត្រៃយ៍ជាជនជាតិខ្មែរ ដែលមានចំនួនសមស្របតាមទំហំពលករប្រចាំនៅប្រទេសទទួលពលករ ដែលបានទទួលការបណ្តុះបណ្តាលឲ្យមានសមត្ថភាពលើចំណេះដឹងផ្លូវច្បាប់ ភាសា វប្បធម៌ ប្រពៃណីរបស់ប្រទេសទទួលពលករ ដែលមានការបញ្ជាក់និងទទួលស្គាល់ពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ តំណាងអចិន្ត្រៃយ៍នេះមិនត្រូវស្ថិតនៅក្រោមឥទ្ធិពលរបស់ក្រុមហ៊ុនជាដៃគូក្នុងប្រទេសទទួលទេ។

**ប្រការ៣.-**

ទីភ្នាក់ងារជ្រើសរើសឯកជន ត្រូវផ្តល់សេវាជូនពលករដែលត្រូវបានដាក់ឲ្យធ្វើការនៅបរទេស មានជាអាទិ៍:

-ត្រូវទៅពិនិត្យកន្លែងធ្វើការងារ និងធ្វើរបាយការណ៍ជូនក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មុននឹងបញ្ជូនពលករ។

-ជូនពលករម្នាក់ៗឲ្យទៅដល់កន្លែងធ្វើការ និងទទួលការណែនាំតម្រង់ទិសនៅប្រទេសទទួល និងការប្រគល់ពលករជូននិយោជក ដោយមានឯកសារត្រឹមត្រូវ។

-ជួយពលករម្នាក់ៗឲ្យទទួលបានរបបសន្តិសុខសង្គមស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាននៃប្រទេសទទួលពលករ

-ជួយពលករម្នាក់ៗក្នុងការបើកគណនីផ្ទាល់ខ្លួន នៅធនាគារណាមួយដែលជិតជាងគេ តាមការជ្រើសរើសរបស់សាមីពលករ និងការពិនិត្យមើលការបញ្ចូលប្រាក់ឈ្នួលរបស់ពលករ

-តាមឃ្លាំមើលជាប្រចាំ ដើម្បីបានដឹងសុខទុក្ខរបស់ពលករ ផ្តល់សេវាជូនពលករតាមតម្រូវការនិងទាន់ពេល និងរាយការណ៍ជូនក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងស្ថានឯកអគ្គរាជទូត ឬស្ថានតំណាងកម្ពុជាប្រចាំប្រទេសទទួល

-ជួយសម្របសម្រួលជាមួយនិយោជកដើម្បីឲ្យពលករមានលទ្ធភាពអាចទំនាក់ទំនងជាមួយក្រុមគ្រួសារបាន

-ត្រូវផ្តល់សេវាប្រឹក្សា និងពិគ្រោះយោបល់ទៅលើលក្ខខណ្ឌការងារ ដោយរាប់បញ្ចូលហានិភ័យដែលអាចកើតមានឡើង ពាក់ព័ន្ធនឹងសុខភាព និងសុវត្ថិភាពការងារ សិទ្ធិ និងភារកិច្ចរបស់ពលករ ព្រមទាំងយន្តការក្នុងការដោះស្រាយវិវាទ។

**ប្រការ៤**.-

ក្នុងករណីកើតមានវិវាទការងារ ទីភ្នាក់ងារជ្រើសរើសឯកជនត្រូវចាត់ចែង សម្របសម្រួល និងដោះស្រាយឲ្យបានទាន់ពេលវេលាទៅតាមនីតិវិធី ដែលបានកំណត់ដោយច្បាប់ និងបទបញ្ញានៃប្រទេសទទួលពលករដើម្បីការពារផលប្រយោជន៍របស់ពលករឲ្យបានខ្ពស់បំផុត។

ក្នុងករណីដែលវិវាទការងារមិនអាចដោះស្រាយបានដោយការផ្សះផ្សា ឬសម្រុះសម្រួល ទីភ្នាក់ងារជ្រើសរើសឯកជនត្រូវរាយការណ៍ជូនស្ថានឯកអគ្គរាជទូត ឬស្ថានតំណាងកម្ពុជាប្រចាំប្រទេសទទួលពលករ និងរកសេវាផ្លូវច្បាប់ជូនពលករ។ រាល់ការចំណាយជាបន្ទុករបស់ទីភ្នាក់ងារជ្រើសរើសឯកជន។

**ប្រការ៥**.-

ក្នុងករណីមានការរំលោភបំពានផ្សេងៗទៅលើពលករ ទីភ្នាក់ងារជ្រើសរើសឯកជនត្រូវជួយពលករក្នុងការចាត់ចែងពាក្យបណ្តឹង និង រាយការណ៍បន្ទាន់ជូនស្ថានឯកអគ្គរាជទូត ឬស្ថានតំណាងកម្ពុជាប្រចាំនៅប្រទេសទទួលពលករ និងអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសទទួលពលករ ដើម្បីដោះស្រាយទៅតាមនីតិវិធីជាធរមាន។

**ប្រការ៦.-**

ក្នុងករណីពលករបាត់ខ្លួននៅក្នុងអំឡុងពេលអនុវត្តកិច្ចសន្យាការងារ ទីភ្នាក់ងារជ្រើសរើសឯកជនត្រូវប្រើប្រាស់គ្រប់វិធីដែលអាចធ្វើទៅបានដើម្បីស្វែងរកពលករ ដោយត្រូវជូនដំណឹងជាលាយលក្ខអក្សរជាបន្ទាន់ ជូនស្ថានឯកអគ្គរាជទូត ឬស្ថានតំណាងកម្ពុជាប្រចាំនៅប្រទេសទទួលពលករ អាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសទទួលពលករ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងមហាផ្ទៃនៃព្រះរាជាណាចក្រកម្ពុជា។

ទីភ្នាក់ងារជ្រើសរើសឯកជន ត្រូវសហការជាមួយស្ថានឯកអគ្គរាជទូត ឬស្ថានតំណាងកម្ពុជាប្រចាំនៅប្រទេសទទួលពលករ និងអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសទទួលពលករ ដើម្បីទទួលបានឯកសារផ្លូវការស្តីពីការបាត់ខ្លួនរបស់ពលករ និងជូនដំណឹងជាលាយលក្ខអក្សរមកក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងមហាផ្ទៃនៃព្រះរាជាណាចក្រកម្ពុជានិងក្រុមគ្រួសាររបស់ពលករ ដោយបញ្ជាក់ឲ្យបានច្បាស់លាស់អំពីព័ត៌មាននៃការបាត់ខ្លួនរបស់ពលករ និងកិច្ចសហប្រតិបត្តិការជាមួយអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ។

ក្នុងករណីដែលទីភ្នាក់ងារជ្រើសរើសឯកជនទទួលបានព័ត៌មានច្បាស់លាស់ អំពីវត្តមានរបស់ពលករដែលបានបាត់ខ្លួន ទីភ្នាក់ងារជ្រើសរើសឯកជនត្រូវជូនដំណឹងជាលាយលក្ខអក្សរជាបន្ទាន់ដល់ក្រុមគ្រួសាររបស់ពលករដើម្បីជ្រាបជាព័ត៌មាន និង ស្ថានឯកអគ្គរាជទូត ឬស្ថានតំណាងកម្ពុជាប្រចាំនៅប្រទេសទទួលពលករ អាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសទទួលពលករ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងមហាផ្ទៃនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីចាត់ការទៅតាមករណីនីមួយៗ។

**ប្រការ៧.-**

ក្នុងករណីពលករទទួលមរណភាព ទីភ្នាក់ងារជ្រើសរើសឯកជនត្រូវជូនដំណឹងជាលាយលក្ខអក្សរជាបន្ទាន់ ជូនស្ថានឯកអគ្គរាជទូត ឬស្ថានតំណាងកម្ពុជាប្រចាំនៅប្រទេសទទួលពលករ អាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសទទួលពលករ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងមហាផ្ទៃ នៃព្រះរាជាណាចក្រកម្ពុជានិងក្រុមគ្រួសារ

របស់ពលករ និងត្រូវស្វែងរកអន្តរាគមន៍ និងរកដំណោះស្រាយទៅតាមនីតិវិធីច្បាប់ជាធរមាន ដោយត្រូវការពារផលប្រយោជន៍របស់ពលករឲ្យបានខ្ពស់បំផុត។

ការបញ្ជូនសព ឬអដ្ឋិធាតុ អត្ថប្រយោជន៍ និងសំភារៈដែលជាកម្មសិទ្ធិរបស់សាកសពជូនក្រុមគ្រួសាររបស់សាកសពនៅប្រទេសកម្ពុជាវិញ គឺជាការទទួលខុសត្រូវ និងជាបន្ទុករបស់ទីភ្នាក់ងារជ្រើសរើសឯកជន ដោយសហការជាមួយភាគីពាក់ព័ន្ធ។

**ប្រការ៨.-**

ក្នុងអំឡុងពេលមួយខែមុនពេលពលករត្រូវបញ្ចប់កិច្ចសន្យាការងារ ទីភ្នាក់ងារជ្រើសរើសឯកជន ត្រូវជួយរៀបចំរាល់កិច្ចការចាំបាច់នានាឲ្យបានចប់សព្វគ្រប់ ដើម្បីឲ្យពលករធ្វើមាតុភូមិនិវត្តន៍ដោយជោគជ័យ។

ក្នុងករណីនៅមានបញ្ហាមិនទាន់ដោះស្រាយចប់សព្វគ្រប់មុនកាលបរិច្ឆេទនៃការធ្វើមាតុភូមិនិវត្តន៍ ទីភ្នាក់ងារជ្រើសរើសឯកជន ត្រូវសហការជាមួយស្ថានឯកអគ្គរាជទូត ឬស្ថានតំណាងកម្ពុជាប្រចាំនៅប្រទេសទទួលពលករ និងអាជ្ញាធរមានសមត្ថកិច្ច នៃប្រទេសទទួលពលករ ដើម្បីបន្តដោះស្រាយបញ្ហារហូតដល់ចប់សព្វគ្រប់។ រាល់ការចំណាយជាបន្ទុករបស់ទីភ្នាក់ងារជ្រើសរើសឯកជន។ ជាពិសេសបញ្ហាទាក់ទងនឹងករណីប្រាក់ឈ្នួលដែលពលករត្រូវទទួលបាន តែមិនទាន់បានទទួល ដោយមានការបញ្ជាក់ពីស្ថានឯកអគ្គរាជទូត ឬស្ថានតំណាងកម្ពុជាប្រចាំនៅប្រទេសទទួលពលករ ទីភ្នាក់ងារជ្រើសរើសឯកជនត្រូវទទួលខុសត្រូវបង់ជូនពលករឲ្យបានគ្រប់ចំនួនជាមុនសិន។

ក្នុងករណីដែលពលករដល់ពេលធ្វើមាតុភូមិនិវត្តន៍ ហើយមិនធ្វើមាតុភូមិនិវត្តន៍ ទីភ្នាក់ងារជ្រើសរើសឯកជនត្រូវនាំពលករមកបង្ហាញខ្លួន និងរាយការណ៍នៅស្ថានឯកអគ្គរាជទូត ឬស្ថានតំណាងកម្ពុជាប្រចាំនៅប្រទេសទទួលពលករដើម្បីមានវិធានការបន្ត។ បន្ទាប់មក ទីភ្នាក់ងារជ្រើសរើសឯកជនត្រូវជូនដំណឹងអំពីករណីនេះមកក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងមហាផ្ទៃនៃព្រះរាជាណាចក្រកម្ពុជា និងក្រុមគ្រួសាររបស់ពលករ។

ក្នុងករណីដែលពលករមានជំងឺ ឬរបួសធ្ងន់ធ្ងរ ទីភ្នាក់ងារជ្រើសរើសឯកជនត្រូវផ្តល់ជំនួយចាំបាច់ដល់ពលករក្នុងការរៀបចំ និងការធ្វើមាតុភូមិនិវត្តន៍ដោយសុវត្ថិភាព។

**ប្រការ៩.-**

នៅពេលពលករធ្វើមាតុភូមិនិវត្តន៍មកដល់ព្រះរាជាណាចក្រកម្ពុជា ទីភ្នាក់ងារជ្រើសរើសឯកជនត្រូវរៀបចំ និងសម្របសម្រួលឲ្យពលករទទួលបានលិខិតបញ្ជាក់ទទួលស្គាល់អតីតភាពការងារ ដែលពលករបានអនុវត្តនៅក្នុងប្រទេសទទួលដែលចេញឲ្យដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**ប្រការ១០.-**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានការងារ អគ្គនាយកនៃអគ្គនាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈ អគ្គាធិការនៃអគ្គាធិការដ្ឋាន អង្គភាពក្រោមចំណុះក្រសួង និងទីភ្នាក់ងារជ្រើសរើសឯកជន ត្រូវអនុវត្តប្រកាសនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខា នេះតទៅ។

**រដ្ឋមន្ត្រី**

**ឥត សុខ**

***កន្លែងទទួល:***

*-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
*-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
*-ទីស្តីការគណៈរដ្ឋមន្ត្រី*
*-ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ*
*-ក្រសួងមហាផ្ទៃ*
*-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*
*-គ្រប់សាលារាជធានី និងខេត្ត*
*" ដើម្បីជូនជ្រាប*
*-ដូចប្រការ១៣ " ដើម្បីអនុវត្ត*
*-ឯកសារ-កាលប្បវត្តិ*